# បដិមារកឃើញថ្មីនៅតំបន់កំពង់លាន ខេត្តកំពង់ធំ

ដូចដែលបានផ្សព្វផ្សាយគ្រប់រូបភាពយ៉ាងទូលំទូលាយរួចមកហើយថា កាលពីរសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥ មានការប្រទះឃើញដោយចៃដន្យនូវរូបបដិមាមួយអង្គ នៅតំបន់កំពង់លាន ស្ថិតនៅប៉ែកពាយព្យវត្តពង្រចម្ងាយប្រមាណ ៧០០ ម៉ែត្រ ត្រង់ភូមិសាស្ត្រ ភូមិជីមាយ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។ ការប្រទះឃើញដោយចៃដន្យនេះ ក្នុងអំឡុងពេលជីកកកាយដីចំណីស្ពឹងក្នុងប្រតិបត្តិការស្តារនិងពង្រីកស្ទឹងស្ទាប់ឡើងវិញ ដែលទីតាំងរកឃើញនេះមានចម្ងាយត្រឹមតែ ២៥ ម៉ែត្រ ពីច្រាំងស្ទឹងស្ទាប់ប៉ុណ្ណោះ។ អ្នករកឃើញបដិមានេះគឺលោក កាក់ ប៊ុនថន ដែលជាអ្នកបើកបរ Excavator ។ តើបដិមាធ្វើអំពីស្ពាន់នេះ មានអត្តសញ្ញាណ និងលក្ខណៈបែបណាខ្លះ?

បដិមាធ្វើអំពីស្ពាន់ដែលរកឃើញថ្មីនេះ មានកម្ពស់ ៤៣ ស.ម. ទទឹង ២៣ ស.ម. កម្រាស់ ១៣ ស.ម. និងទម្ងន់ ២០ គ.ក.។ បដិមានេះមានព្រះហស្ត ២ ដែលក្នុងនោះព្រះហស្តស្តាំបានបាត់បង់ត្រឹមកែង និងព្រះឆ្វេងនៅរក្សារូបរាងល្អក្នុងកាយវិការកំពុងកាន់របស់អ្វីមួយ ដោយយកម្រាមមេដៃទៅប៉ះជាមួយម្រាមកណ្ដាល។ សិល្បកររចនាឡើងក្នុងទម្រង់ឈរជំហរត្រង់ មានព្រះភក្ត្រមូល ព្រះកាណ៌វែង (ត្រចៀក) ព្រះនេត្របិទ ចិញ្ចើមជាប់គ្នាវែង បបូរមាត់ក្រាស់ ពុកមាត់ងរឡើងលើ និងតុបតែងព្រះកេសជាទម្រង់ជដាមកុដ (មកុដរាងផ្នួងសក់) ពោលគឺជាប្រភេទសក់រួញក្រញាញ់ស្រដៀងគូទខ្យង ដែលជានិមិត្តរូបមួយក្នុងចំណោមនិមិត្តរូបទាំង៣២ នៃមហាបុរិសលក្ខណៈរបស់ព្រះពុទ្ធ។ លក្ខណៈសក់បែបនេះ គឺតំណាងឱ្យភាពពិសិដ្ឋ និងសេចក្ដីល្អឥតខ្ចោះ។ គួរឱ្យសោកស្ដាយ ត្រង់ចំណុចផ្នួងសក់ និងថ្ងាសរបស់បដិមាស្ពាន់នេះមានការបែកបាក់ ដែលនាំឱ្យពិបាកក្នុងការកំណត់អត្តសញ្ញាណរបស់ទេព។ ដ្បិត ត្រង់ចំណុចថ្ងាស និងផ្នួងសក់ យើងងាយនឹងកំណត់អត្តសញ្ញាណទេព ទាំងក្នុងព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនា។ ជាក់ស្ដែង នៅក្នុងសិល្បៈខ្មែរ បដិមាព្រះពោធិសត្វអវលោកិតេស្វរ (លោកេស្វរ) តែងមានព្រះនេត្រទីបីតូចមួយនៅលើថ្ងាស និងមានចម្លាក់ព្រះពុទ្ធអមិតាភៈតូចមួយនៅលើផ្នួងសក់ រីឯព្រះពោធិសត្វមៃត្រេយ (សិអារ្យមេត្រិយ) តែងមានព្រះនេត្រទីបីនៅលើថ្ងាសដូចគ្នា តែខុសត្រង់នៅលើផ្នួងសក់មានរូបចេតិយឬស្តូបតូចមួយ។ ចំណែកឯ នៅក្នុងព្រហ្មញ្ញសាសនាវិញ ព្រះឥសូរតែងមានព្រះនេត្រទីបីនៅលើថ្ងាស និងមានចំណិតព្រះចន្ទនៅលើផ្នួងសក់។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី តាមការសន្និដ្ឋានជាបឋម បដិមាធ្វើអំពីស្ពាន់ដែលរកឃើញនៅតំបន់កំពង់លាននេះ ប្រហែលជារូបតំណាងនៃទេពក្នុងព្រះពុទ្ធសាសនាមហាយាន ច្រើនជាងរូបតំណាងឱ្យទេពក្នុងព្រហ្មញ្ញសាសនា (ព្រះឥសូរ) ពោល គឺទំនងជាព្រះពោធិសត្វអវលោកិតេស្វរ (លោកេស្វរ) ឬព្រះពោធិសត្វមៃត្រេយ (សិអារ្យមេត្រិយ)។ ការសន្និដ្ឋានដូច្នេះ គឺយោងទៅលើទិដ្ឋភាពទូទៅក្នុងសង្គមខ្មែរនៅសម័យបុរាណ គឺមានការគោរពប្រណិប័តន៍ព្រះពោធិសត្វទាំងពីរនេះតាំងពីយូរណាស់មកហើយ ពោល យ៉ាងហោចណាស់ក៏ស.វ.ទី៦ ឬទី៧មកដែរ ដូចដែលសិលាចារឹកប្រាសាទអំពិលរលំ (ចុងស.វ.ទី៧ ដើមស.វ.ទី៨) ចុះបញ្ជីលេខ K.163 ដែលរៀបរាប់អំពីតង្វាយរបស់បោញប្រាជ្ញាចន្រ្ទ និងបោញវិទ្យា ថ្វាយចំពោះព្រះកម្រតេងអញមៃត្រេយ និងកម្រតេងអញអវលោកិតេស្វរ ដែលសុទ្ធសឹងជាព្រះពោធិសត្វក្នុងព្រះពុទ្ធសាសនាមហាយាន។ ព្រះពោធិសត្វអវលោកិតេស្វរ (លោកេស្វរ) ជាព្រះពោធិសត្វដ៏សំខាន់ និងមានប្រជាប្រិយបំផុតនៅក្នុងព្រះពុទ្ធសាសនានិកាយមហាយាន តំណាងឱ្យសេចក្តីមេត្តាករុណាដ៏ជ្រាលជ្រៅ និងជាព្រះដែលចុះមកសង្រ្គោះសត្វលោក។ ជាទូទៅ ព្រះពោធិសត្វអវលោកិតេស្វរ មានព្រះហស្តពីរដូច្នេះ ច្រើនកាន់ផ្កាឈូក និងក្អមទឹក។ ផ្កាឈូក ជានិមិត្តរូបតំណាងឱ្យភាពបរិសុទ្ធ និងសេចក្តីមេត្តាធម៌ ដែលដុះចេញពីភក់ជ្រាំ (តំណាំងឱ្យទុកវេទនារបស់សត្វលោក) រីឯក្អមទឹក តំណាងឱ្យទឹកអម្រឹតដែលអាចលាងជម្រះបាបកម្មសត្វលោក និងនាំមកនូវភាពបរិសុទ្ធ។

ក្រឡេកមកមើលសំពត់របស់បដិមាវិញ សិល្បករតុបតែងសំពត់ខ្លីចង់ក្បិន មានក្លី ជាយសំពត់ធ្លាក់សំយាកមកគ្របលើភ្លៅខាងឆ្វេង និងមានជាយតូចមួយធ្លាក់ទៅចំហៀងលើភ្លៅខាងស្តាំ ហើយចងរុំព័ទ្ធចង្កេះដោយខ្សែក្រវ៉ាត់មួយ។ លក្ខណៈបែបនេះមានភាពស្រដៀងច្រើនទៅនឹងរចនាបថគូលែន និងរចនាបថព្រះគោ ប៉ុន្តែខុសត្រង់ថា សិល្បៈរចនាបថគូលែន និងព្រះគោសំពត់របស់បដិមាពុំមានក្លីនោះទេ។ ម្យ៉ាងវិញទៀត នៅក្នុងរជ្ជកាលព្រះបាទស្រីជ័យវរ្ម័នទី២ ដល់រជ្ជកាលព្រះបាទស្រីឥន្ទ្រវរ្ម័នទី១ ក៏ពុំសូវមានព័ត៌មានជាប់ពាក់ព័ន្ធជាមួយព្រះពុទ្ធសាសនានោះដែរ។ ប៉ុន្តែ បើយើងប្រៀបធៀបជាមួយសិល្បៈរចនាបថបាខែង (គ.ស.៨៩៣ ដល់ ៩២៥) ដែលត្រូវនឹងរជ្ជកាលព្រះបាទស្រីយសោវរ្ម័នទី១ (គ.ស.៨៨៩ ដល់ ៩១០) និងរជ្ជកាលព្រះបាទស្រីហស៌វរ្ម័នទី១ (គ.ស.៩១០ ដល់ ៩២៥?) វិញ យើងឃើញថាមានភាពស្រដៀងច្រើន ពោល គឺត្រង់ក្លីសំពត់តែម្តង បើទោះបីសំពត់បដិមានេះពុំមានជាយធ្លាក់ពីរជាន់នៅចំកណ្តាលដូចបដិមាផ្សេងៗ ដែលរកឃើញនៅប្រាសាទភ្នំក្រោម និងភ្នំបូកក៏ដោយ។ ជាពិសេសនោះ វាស្របទៅតាមទិដ្ឋភាព

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

នៅសម័យនោះ (ចុងស.វ.ទី៩ និងដើមស.វ.ទី១០) ដែលគេធ្លាប់ប្រទះឃើញបដិមាព្រះពោធិសត្វលោកេស្វរ ធ្វើអំពីស្ពាន់ និងសំរិទ្ធជាច្រើន។ ដូច្នេះហើយ យើងអាចសន្និដ្ឋានបឋមថា បដិមាដែលរកឃើញថ្មីនេះ អាចសិតឡើងនៅរវាងចុងស.វ.ទី៩ ដល់ដើមស.វ.ទី១០។

ជារួមមក បដិមាធ្វើអំពីស្ពាន់ដែលបានរកឃើញថ្មីនៅតំបន់កំពង់លាន ស្រុកសន្ទុក ខេត្តកំពង់ធំ ទំនងជារូបតំណាងឱ្យទេពនៅក្នុងលទ្ធិព្រះពុទ្ធសាសនាមហាយាន ដែលអាចជាព្រះពោធិសត្វអវលោកិតេស្វរ (លោកេស្វរ) ឬព្រះពោធិសត្វមៃត្រេយ (សិអារ្យមេត្រិយ) ហើយទំនងសិតឡើងនៅរវាងចុងស.វ.ទី៩ ដល់ដើមស.វ.ទី១០ ពោល គឺទំនងស្ថិតនៅក្នុងរជ្ជកាលព្រះបាទស្រីយសោវរ្ម័នទី១ (គ.ស.៨៨៩-៩១០) ឬព្រះបាទហស៌វរ្ម័នទី (គ.ស.៩១០-៩២៥ ?)។ ម្យ៉ាងវិញទៀត ទីតាំងដែលបានរកឃើញបដិមានេះ គឺសម្បូណ៌ដោយប្រាសាទបុរាណ និងទួលបុរាណជាច្រើន ដែលអាចសបញ្ជាក់ឱ្យឃើញថា កាលពីសម័យអង្គរ ទីតាំងនេះអាចទីប្រជុំជនមានមនុស្សរស់នៅកុះករ និងមានជំនឿប្រណិប័តន៍ព្រះពុទ្ធសាសនាមហាយានជាយូរមកហើយ។

## ឯកសារពិគ្រោះ


Aymonier, E. 1900. *Le Cambodge*, Tome I, Paris.

Bunker, E.C. & Latchford, D. 2011. *Khmer Bronzes: New Interpretations of the Past.* Chicago: Art Media Resources

Boisselier, J. 1966. *Asie du Sud-Est, Le Cambodge,* Tome I, Paris.
Coedès, G. 1954. *Inscription du Cambodge*, Vol VI, Hanoi.

Lajonquière, L. 1902. *Inventaire descriptive des monuments du Cambodge*, Tome I, Paris.

Nandana, C. 1984. *The Iconography of Avalokiteśvara in Mainland South East Asia*. Leiden: D. Litt. Diss.


AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ បដិមាព្រះពោធិសត្វអវលោកិតេស្វរ ឬព្រះពោធិសត្វមៃត្រេយ
រកឃើញថ្មីនៅភូមិដីមាយ ឃុំកកោះ ស្រុកសន្ទុក

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២២៖ លម្អិតបដិមាត្រឹមដងខ្លួន



រូបលេខ២៣៖ លម្អិតព្រះភក្ត្រ (មើលចំពីមុខ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៦៖ លម្អិតព្រះភក្ត្រ (មើលពីចំហៀង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៥ និង៦ ៖ លម្អិតសំពត់ចង់ក្បិនព្រះពោធិសត្វអវលោកិតេស្វរ ឬព្រះពោធិសត្វមៃត្រេយ
(មើលពីមុខ និងក្រោយ)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី